# ព័ត៌មានសំខាន់អំពីការធានារ៉ាប់រង MEDICAID របស់អ្នក

## សូមចាត់វិធានការភ្លាម

យើងកំពុងសរសេរព័ត៌មានសំខាន់ៗអំពីអត្ថប្រយោជន៍សុខភាព Medicaid របស់អ្នក។ ដូចដែលបានតម្រូវដោយច្បាប់សហព័ន្ធ រដ្ឋ Rhode Island កំពុងធ្វើការបន្តសិទ្ធិទទួលបាន Medicaid ដើម្បីបញ្ជាក់ថា អ្នកគ្រប់គ្នាដែលទទួលបាន Medicaid នៅតែមានសិទ្ធិទទួលបានដដែល។ កំណត់ត្រារបស់យើងបង្ហាញថា អ្នកមានកាលៈទេសៈពិសេសដែលប៉ះពាល់ដល់សិទ្ធិទទួលបានរបស់អ្នក។

**ការធានារ៉ាប់រង Medicaid របស់អ្នកបានបញ្ចប់**

ព័ត៌មានដែលយើងមាន ចង្អុលបង្ហាញថា អ្នកមិនមានសិទ្ធិទទួលបាន Medicaid ដោយសារតែស្ថានភាពអន្តោប្រវេសន៍របស់អ្នក។ យើងបានព្យាយាមពិនិត្យមើលស្ថានភាពអន្តោប្រវេសន៍របស់អ្នកតាមរយៈប្រភពដែលមានស្រាប់របស់យើងខ្ញុំ ប៉ុន្តែយើងមិនអាចបញ្ជាក់ស្ថានភាពរបស់អ្នកបានទេ។ យើងមិនមានឯកសារដែលយើងត្រូវមើលថាតើអ្នកមានសិទ្ធិបន្តទទួលបានការធានារ៉ាប់រងឬអត់នោះទេ។

**របៀបស្វែងយល់ថាតើអ្នកអាចបន្តទទួលបាន Medicaid ឬអត់**

ប្រសិនបើអ្នកចង់បន្តទទួលបានការធានារ៉ាប់រងពី Medicaid សូមផ្តល់ឯកសារដែលយើងត្រូវការ ដើម្បីកំណត់សិទ្ធិទទួលបាន Medicaid របស់អ្នក។ អ្នកអាចស្វែងយល់បន្ថែមអំពីឯកសារដែលយើងត្រូវការដោយៈ

- ការឡុកចូលទៅកាន់គណនីរបស់អ្នកតាមរយៈ www.healthyrhode.ri.gov។ ទំព័រ My Dashboard (ផ្ទាំងគ្រប់គ្រងរបស់ខ្ញុំ) នឹងបង្ហាញឯកសារដែរអ្នកត្រូវតែផ្តល់ជូន។
- ទំនាក់ទំនងទៅក្រសួងសេវាមនុស្សជាតិ (Department of Human Services, DHS) នៃរដ្ឋ Rhode Island តាមរយៈលេខ 1-855-697-4347។

កុំបង្អង់យូរ។ សូមពិនិត្យមើលឯកសាររបស់អ្នក និងផ្តល់ជូនព័ត៌មានថ្មីៗភ្លាមៗ ដើម្បីឱ្យយើងអាចកំណត់ថាតើអ្នកមានសិទ្ធិបន្តទទួលបានការធានារ៉ាប់រងដែរឬទេ។

**<u>អ្វីដែលអ្នកអាចធ្វើបានប្រសិនបើអ្នកលែងមានសិទ្ធិទទួលបាន Medicaid ទៀតហើយ</u>**
ប្រសិនបើអ្នកមានវត្តមានស្របច្បាប់នៅក្នុងសហរដ្ឋអាមេរិក និងបំពេញតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានពីស្ថានភាពអន្តោប្រវេសន៍ អ្នកអាចមានជម្រើសផ្សេងទៀតសម្រាប់ការបន្តទទួលបានការធានារ៉ាប់រងតាមរយៈ HealthSource RI (HSRI)។ ទូរសព្ទទៅ HSRI ពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 ល្ងាច នៅថ្ងៃធ្វើការតាមរយៈលេខ 1-855-840-4774 ដើម្បីជជែកជាមួយអ្នកណាម្នាក់ដែលអាចជួយអ្នកបាន។

ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចរបស់យើងអំពីអត្ថប្រយោជន៍របស់អ្នកទេ អ្នកអាចប្តឹងឧទ្ធរណ៍ដោយអនុវត្តតាមដំណើរការដែលបានពិពណ៌នានៅក្នុងសេចក្តីជូនដំណឹងអំពីសេក្តីសម្រេចអំពីអត្ថប្រយោជន៍របស់អ្នក (Benefits Decision Notice)។

ចូលមើល www.staycovered.ri.gov ដើម្បីស្វែងយល់បន្ថែមអំពីសិទ្ធិទទួលបាន Medicaid និងរបៀបស្វែងរកជំនួយ។